លេខ ១ ខែកក្កដា ឆ្នាំ ២០០៦

**ក្នុងអត្ថបទចេញផ្សាយនេះមាន**

- ការជួញដូរពស់ទឹក
- ក្របខណ្ឌគោលនយោបាយរួមរបស់ថបនីយជីវមណ្ឌលបឹងទន្លេសាប
- អង្គការក្រៅរដ្ឋាភិបាលនាពេលបច្ចុប្បន្ន

# ព្រឹត្តិបត្រ
# ថបនីយជីវមណ្ឌលបឹងទន្លេសាប






**លេខ១ កក្កដា ឆ្នាំ២០០៦**

រូបគម្របមុខ : ភូមិបណ្តែតទឹក នៅព្រែកទាល់ បឹងទន្លេសាប
ថតដោយ : Sonja Endlweber

បោះពុម្ពដោយ លេខាធិការដ្ឋានថបនីយជីវមណ្ឌលបឹងទន្លេសាប
ផ្ទះលេខ ៣៦៤ មហាវិថីព្រះមុនីវង្ស ភ្នំពេញ កម្ពុជា
ទូរស័ព្ទ : (៨៥៥-០២៣) ២២១០៧៩
អ៊ីមែល : secretariat@tsbr-ed.org

ឯកសារបោះពុម្ពនេះ គឺជាផ្នែកមួយនៃគំរោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាប ក្រោមកម្ចីហិរញ្ញប្បទានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ចំពោះរាជរដ្ឋាភិបាលកម្ពុជា

រៀបរៀងដោយ លោក បណ្ឌិត នៅ បោនន័រ និង Sonja Endlweber
បកប្រែដោយ : ពេជ្រ សុខដានី និង សាន ផល្លា
ពិនិត្យកែសំរួលដោយ : ពេជ្រ សុខដានី និង លី សុភ័ណ្ឌ
បោះពុម្ពដោយ : រោងពុម្ព គីម ឡុង
តាក់តែង និងរចនាដោយ : Karen Young
អង្គការ ការអប់រំស្តីពីការរស់នៅជាមួយបរិស្ថាន

ប្រសិនបើអស់លោក លោកស្រីចង់ចូលរួមផ្សព្វផ្សាយអត្ថបទ ព្រឹត្តិការណ៍ ឬឯកសារ ឬផ្តល់យោបល់លើអត្ថបទណាមួយនោះ សូមទំនាក់ទំនងតាមទូរស័ព្ទ :
(៨៥៥-០២៣) ២២១០៧៩

## លិខិតពីអ្នករៀបរៀង



ថបនីយជីវមណ្ឌលបឹងទន្លេសាប ជាសម្បត្តិធម្មជាតិដ៏មានតំលៃបំផុតមួយរបស់ប្រទេសកម្ពុជា។ វាផ្តល់នូវសារជាតិប្រូតេអ៊ីនពីត្រី និងប្រពន្ធ័ធារាសាស្ត្រដល់ប្រជាជនមួយផ្នែកធំនៅប្រទេសកម្ពុជា ព្រមទាំងទទួលបាននូវ[illegible]ភាពចំពោះភាពសំបូរបែបនៃជីវចម្រុះនេះ។ លេខាធិការដ្ឋានត្រូវបានបង្កើតឡើងដើម្បីផ្តល់នូវការសំរបសំរួល ទំនាក់ទំនង និងការផ្លាស់ប្តូរចំណេះដឹងក្នុងចំណោមអ្នកពាក់ពន្ធ័ទាំងអស់។

ព្រឹត្តិបត្រថបនីយជីវមណ្ឌលបឹងទន្លេសាប ដែលបោះពុម្ពដោយលេខាធិការដ្ឋានថបនីយជីវមណ្ឌលបឹងទន្លេសាប គឺជាផ្នែកមួយនៃយុទ្ធសាស្ត្ររួម ដើម្បីបង្កើនចំណេះដឹង និងការយល់ដឹងក្នុងចំណោមថ្នាក់ដឹកនាំ មន្ត្រីជំនាញ និងសាធារណៈជន អំពីភាពសំបូរបែប និងតំលៃនៃប្រពន្ធ័អេកូឡូស៊ីធម្មជាតិ ដោយផ្តល់អោយពួកគាត់នូវព័ត៌មានទូលំទូលាយ និងថ្មីៗ។ ព្រឹត្តិបត្របឹងទន្លេសាបនេះ គឺជាលទ្ធផលបន្ទាប់បន្សំមួយនៃផ្នែកទិន្នន័យ-ព័ត៌មានថបនីយជីវមណ្ឌលបឹងទន្លេសាប ដែលឧបត្ថម្ភដោយគំរោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាប។

ចាប់ពីព័ត៌មានពីការសិក្សាស្រាវជ្រាវតាមបែបវិទ្យាសាស្ត្ររហូតដល់ការរីកចំរើនរបស់គំរោង និងព័ត៌មានផ្សេងៗ ដែលទទួលបានពីបណ្តាអ្នកពាក់ពន្ធ័ដែលធ្វើការងារនៅក្នុងថបនីយជីវមណ្ឌល ព្រឹត្តិបត្រមានគោលបំណងនាំមកនូវប្រធានបទដែលគួរអោយចាប់អារម្មណ៍បំផុត រឿងរ៉ាវ និងបញ្ហាសំខាន់ៗដែលបឹងទន្លេសាបជួបប្រទះ។ លើសពីនេះ ព្រឹត្តិបត្រនេះនឹងផ្តល់នូវរឿងខ្លីៗអំពីជីវិតរបស់ប្រជាជននៅជនបទ ដែលរស់នៅពឹងផ្អែកលើធនធានធម្មជាតិនៃបឹងទន្លេសាប។ វាគឺជាវេទិកាសំរាប់ការពិភាក្សា និងការតស៊ូមតិ តាមរយៈការចែករំលែកទស្សនៈ និងកង្វល់ពីបុគ្គល អ្នកវិទ្យាសាស្ត្រ និងក្រុមការងារសង្គម។ ពុំមានការសង្ស័យថា ព័ត៌មាន និងទិន្នន័យជាក់លាក់នេះជាម៉ាស៊ីនជំរុញដំណើរការវិវត្តន៍នៅគ្រប់ផ្នែកនៃសង្គមនោះឡើយ។

យើងខ្ញុំស្វាគមន៍ជានិច្ចនូវរាល់ការចែករំលែកជាអត្ថបទ របាយការណ៍ រឿងរ៉ាវផ្សេងៗ ដែលទាក់ទងនឹងជីវភាពរស់នៅ និងលទ្ធផលគំរោង។ យើងខ្ញុំរីករាយនឹងទទួលយកនូវរាល់អនុសាសន៍របស់លោកអ្នកទៅលើការចេញផ្សាយនេះ។

ព្រឹត្តិបត្រនេះមាននៅក្នុងគេហទំព័រ : www.tsbr-ed.org

យើងខ្ញុំសង្ឃឹមថា ព្រឹត្តិបត្រថបនីយជីវមណ្ឌលបឹងទន្លេសាបនឹងផ្តល់ទាំងព័ត៌មាន និងអ្វីដែលគួរអោយចាប់អារម្មណ៍ដល់លោកអ្នក។

ប្រសិនបើអស់លោក លោកស្រីចង់ចូលរួមក្នុងបញ្ជីអ៊ីមែល និងចង់ទទួលបានព្រឹត្តិបត្រជាអេឡិចត្រូនិចហ្វាល របស់លេខាធិការដ្ឋានថបនីយជីវមណ្ឌលបឹងទន្លេសាប សូមផ្ញើ អ៊ីមែលមកកាន់ :
secretariat@tsbr-ed.org
ព្រឹត្តិបត្រនេះអាចទាញយកតាមវេបសាយ www.tsbr-ed.org

# TONLE SAP
BIOSPHERE RESERVE
# BULLETIN
VOLUME 1 JULY 2006

AIDOC



# CONTENTS

WATER BIRD CONSERVATION .......... 2

WATER SNAKE TRADE .......... 4

PROJECTS

- » TSBR Common Policy Framework and Coordination Mechanism .......... 6
- » Tonle Sap Environmental Management Project .......... 9
- » Champions of their World .......... 10
- » Environmental Education .......... 11
- » Environmental Information Database .......... 11
- » The Community Fishery in Spien Krong Village .......... 12
- » Update from the PIU Kampong Chhnang .......... 13
- » Training for a better biodiversity management of TSBR Core Areas .......... 14
- » Supporting sustainable livelihoods in the TSBR core areas .......... 15
- » Community Theatre at the Heart of Cambodia .......... 16

NGO NEWS .......... 17

BIOSPHERE RESERVES IN VIETNAM .......... 20

PUBLICATIONS .......... 22

CALENDAR OF EVENTS .......... 23

# WATER BIRD CONSERVATION

AIDCC
Code:
Date:
Donated by:

## A success story in Prek Toal core area

There has been - and continues to be - much written about the Tonle Sap Great Lake. It began more than a decade ago with one or two articles raising people's attention of the importance of the lake. Nowadays, it's commonplace to find coverage in regional travel magazines, television/ radio programs, and international newspapers.

For the most part these stories are announcing the unique features of the lake, or highlighting social and environmental challenges. What are conspicuous by their absence are stories with hard data on what has actually been achieved on the lake by the myriad of social, developmental and environmental projects. Until now.

One particular project is now able to show – using more than four years of comparable data - results worth writing about. In the Prek Toal Wildlife Sanctuary, one of the three core areas of the Tonle Sap Biosphere



Reserve and also a major Fishing Lot, Cambodia can boast South East Asia's most dramatic wildlife recovery success story.

**Table 1.** Provides just one example of why Prek Toal now has global standing in conservation.

Prek Toal also now contains South East Asia's largest colonies of seven Globally Threatened or Near Threatened large waterbirds.

A detailed monitoring program is able to confidently show upwards trends in many of these populations and downward trend in destructive activities, providing clear evidence of the success of the project over time. This monitoring is essential not just to say 'we're succeeding' but in being able to adapt management interventions to account for changes in threats and the colonies themselves.

As with most conservation success stories, the project has humble beginnings. Surveys in 1994 first identified Prek Toal as a site of importance for large waterbirds, but also warned that uncontrolled egg collection was threatening the complete extermination of these endangered species. Further visits determined that immediate action had to be taken; that a multi-year project development period would come too late. So, with small-scale support of the Wildlife Conservation Society (WCS) a handful of dedicated national and international conservationists set out to find ways to save the colonies. Five years later, Prek Toal now boasts the region's most important site for large waterbirds, with recoveries of a host of Globally Threatened species. This is even more remarkable for the fact that this is in a region where decline and extinction are the dominant trends.

Aside from the obvious success of the wildlife recoveries, there are two other reasons to take note of this project: it was and still is run on a very small budget, and it has demonstrably contributed to improving local livelihoods in Prek Toal. In 1999,




Table 1. The table shows the population increase of the Oriental Darter over four years. Prek Toal now contains the world's largest single colony of the species.

ក្រៅពីជោគជ័យខាងលើនៃការស្ការសត្វព្រៃ មានហេតុផលពីរ ផ្សេងទៀតដើម្បីសំគាល់ពីគំរោងនេះ : វាបាន និងកំពុងតែដំណើរការ ក្រោមថវិកាតិចតួច និងត្រូវបានបន្តចែករំលែកដើម្បីបង្កើនជីវភាពប្រជាពលរដ្ឋនៅមូលដ្ឋាននៅព្រែកទាល់។ នៅឆ្នាំ១៩៩៩ ដោយមានកិច្ចសហប្រតិបត្តិការរវាងក្រសួងបរិស្ថាន និងឡូតិ៍នេសាទ អង្គការ WCS បានចាប់ផ្តើមធ្វើការគាំទ្រគំរោងដោយប្រើប្រាស់ថវិកាតែពីរ ទៅបីពាន់ដុល្លានៃថវិការួមរបស់វា (core funds)។ ជាមួយនឹងការតាំងចិត្តមួយដើម្បីធ្វើការងារនៅនឹងកថ្នាក់មូលដ្ឋាន និងការជឿជាក់ថា បញ្ហាក្នុងតំបន់ត្រូវការដំណោះស្រាយក្នុងមូលដ្ឋាន ពួកគេបានចាប់ផ្តើមធ្វើការងារជាមួយប្រជាជនដែលបង្កការគំរាមកំហែងដល់បក្សាយសត្វដែលនៅសល់ : សហគមន៍នេសាទ។ គុណភាពយ៉ាងប្រុងប្រយត្ននៃវិធីសាស្ត្រការ៉ុត (ការងារ និងការប្រមូលប្រាក់កំរៃនៅសហគមន៍) និងដំបង (ការពង្រឹងច្បាប់) ចាប់ផ្តើមផ្លាស់ប្តូរទស្សនៈរបស់ប្រជាជនទៅលើសត្វស្លាបពីជំរើសអាហារក្នុងរយៈពេលខ្លីទៅជាជំរើសមុខរបរចិញ្ចឹមជីវិតក្នុងរយៈពេលវែង។

តាមរយៈការថ្លឹងថ្លែងផ្សេងទៀត គំរោងមានឥទ្ធិពលជាវិជ្ជមានទៅលើការប្រកបរបរចិញ្ចឹមជីវិតរបស់ប្រជាជននៅក្នុងតំបន់។ ជាដំបូង យើងនឹងលើកយកការអនុត្តនៅក្នុងទ្រង់ទ្រាយតូច។ អតីតអ្នកប្រមូលពងសត្វជាង–៣០នាក់ និងគ្រួសាររបស់ពួកគេ (ច្រើនជាង១២០នាក់) បានទទួលផលប្រយោជន៍យ៉ាងជាប់លាប់តាមរយៈការងារអចិន្ត្រៃយ៍នៅក្នុងគំរោងអភិរក្ស។ ទាំងនេះជាប្រភេទតួលេខ–ដែលជាញឹកញាប់ ត្រូវបានមើលរំលងដោយអ្នកជំនាញការអភិវឌ្ឍន៍ ដោយចាត់ទុកថាជាចំនួនតិចតួចដែលមិនចាំបាច់ និងគ្មានចេរភាព។ ទោះជាយ៉ាងណា ប្រាំឆ្នាំក្រោមខ្សែបន្ទាត់គំរោង (វែងជាងគំរោងអភិវឌ្ឍន៍ជាច្រើនទៀត) គ្រួសារទាំងនេះនៅតែត្រូវបានជួល ហើយបច្ចុប្បន្នពួកគេមានធនធាន និងសុវត្ថិភាពអាចវិនិយោគនៅក្នុងការផ្លាស់ប្តូរជំរើសមុខរបរចិញ្ចឹមជីវិតឯករាជភាពពី គំរោង អ្នកផ្តល់ប្រាក់កំចី រឺភ្នាក់ងារផ្តល់ជំនួយ។ ក្នុងលក្ខណៈទ្រង់ទ្រាយធំ ការការពារសត្វស្លាបក៏មានន័យថាជាការការពារ



សត្វពីការអនុវត្តន៍ខុសច្បាប់ និងគ្មានចេរភាព ដូចជាការប្រមូលឈើមូល និងការអនុវត្តការនេសាទដែលមានលក្ខណៈបំផ្លិចបំផ្លាញ។ វាជាការចាប់អារម្មណ៍ដើម្បីកត់សំគាល់ថាជាងបួនឆ្នាំកន្លងមកនេះ ចំនួនអ្នកនេសាទក្នុងតំបន់ដែលចូលមកនេសាទនៅជាយព្រែកទាល់បានកើនឡើង។ ប្រហែលជាមានហេតុផលច្រើនជាងមួយសំរាប់បញ្ហានេះ មិនមែនមកពីការបរាជ័យក្នុងការគ្រប់គ្រងនៅតំបន់ផ្សេងទៀតនៅលើផ្ទៃបឹងនោះទេ ប៉ុន្តែប្រសិនបើអ្នកសួរពួកគេថាហេតុអ្វីបានជាពួកគេនៅទីនេះ ពួកគេនឹងឆ្លើយថា "ពីព្រោះនៅទីនេ–ះមានត្រីច្រើន"។ ចំនួនត្រីនៅតែរក្សាការធ្លាក់ចុះ តែបក្សាយសត្វស្លាបទឹកបាណជួយដល់ការពងកូន និងបង្កើនជីវជាតិទឹក ក្នុងខណៈដែលវិធានការអភិរក្សសមហេតុផលជាច្រើនក៏បានការពារជំរកពងផងដែរ ហេតុដូចនេះទើបវាបង្កើតបានជាការចែកចាយដ៏មានសារៈសំខាន់ទៅដល់សេដ្ឋកិច្ចក្នុងតំបន់។

ជោគជ័យគំរោងធ្វើអោយកើនឡើងនូវសំនួរដែលគួរអោយចាប់អារម្មណ៍ជាច្រើន។ តើគេនិយាយអ្វីអំពីយុទ្ធសាស្ត្រនៃការគ្រប់គ្រងបឹងនាពេលបច្ចុប្បន្ន ដែលជារឿងជោគជ័យមួយស្តីពីជីវិតសត្វ (និងជារឿងមួយនៃជោគជ័យមួយចំនួននៃមុខរបរចិញ្ចឹមជីវិត) ដែលឋិតនៅឡូតិ៍នេសាទមួយ? តើការពិភាក្សាវែកញែកលើបញ្ហាឡូតិ៍នេសាទជាមួយសហគមន៍នេសាទ និងតំបន់ការពារខ្វះចន្លោះចំនុចឬ? បញ្ហាទាំងបីនេះក៏មាននៅព្រែកទាល់។ ជាក់ច្បាស់ គំរោងអភិរក្ស ព្រែកទាល់លេចឡើងដើម្បីផ្តល់ដំណោះខ្លាំងក្លាមួយសំរាប់ការចរចារតាមបែបអនុវត្តរវាងដំណោះទាំងនោះទាក់ទងជាមួយឡូតិ៍នេសាទ ការអភិរក្ស និងសហគមន៍។ គំរោងស្នើថាការអភិរក្សគឺជាជំរើសនៃការអភិវឌ្ឍពិតប្រាកដមួយសំរាប់ទីតាំងខ្លះ និងដែលការអភិរក្សដែលប្រកបដោយការគិតគូរអាចនាំទៅរកជំរើសមុខរបរចិញ្ចឹមជីវិតដែលល្អ។

**អតីតអ្នកប្រមូលពងសត្វជាង៣០នាក់ និងគ្រួសាររបស់ពួកគេ (ច្រើនជាង១២០នាក់) បានទទួលផលប្រយោជន៍យ៉ាងជាប់លាប់តាមរយៈការងារអចិន្ត្រៃយ៍នៅក្នុងគំរោងអភិរក្ស។**

ព័ត៌មានបន្ថែមអំពីអង្គការ សង្គ្រោះសត្វព្រៃនៅទំព័រទី ២០

# ការជួញដូរពស់ទឹក

**ការជួញដូរពស់ទឹកនៅជុំវិញបឹងទន្លេសាបកាន់តែមានសកម្មភាពច្រើនឡើងៗគួរឱ្យកត់សំគាល់ ។ កម្មវិធីត្រួតពិនិត្យដែលបានអនុវត្តកាលពីជាងពីរឆ្នាំមុន បានបង្ហាញឱ្យឃើញថាមានសត្វពស់ជាងបួនលានក្បាលត្រូវបានគេប្រមាញ់ជារៀងរាល់ឆ្នាំ នេះគឺជាការធ្វើអាជីវកម្មធំជាងគេបំផុតនៅក្នុងពិភពលោក ។**

BY SHARON E. BROOKS, EDWARD H. ALLISON, JOHN D. REYNOLDS, TOUCH BUNTHANG, PROKROTEY KHOY



▲ *សត្វពស់កំពុងត្រូវបានគេជួញដូរ នៅខេត្តកំពង់ឃ្លាំងប៉ែកខាងត្បូងបឹងទន្លេសាប*

មានទីផ្សារផ្សេងៗគ្នាមួយចំនួនសំរាប់សត្វពស់បឹងទន្លេសាប។ ដែលគួរអោយកត់សំគាល់នោះគឺការជួញដូរនៅក្នុងតំបន់ ដែលសត្វពស់ទាំងនេះត្រូវបានគេប្រើប្រាស់ជាចំណីសត្វសំរាប់ផ្គត់ផ្គង់សត្វក្រពើនៅតាមកសិដ្ឋានចិញ្ចឹមក្រពើជាច្រើនកន្លែងនៅក្នុង និងជុំវិញបឹងទន្លេសាប។ ការកើនឡើងនូវឧស្សាហកម្មចិញ្ចឹមក្រពើដ៏លើសលប់នៅប្រទេសកម្ពុជាកើតឡើងជាងម្ភៃឆ្នាំមកហើយ (Jelden et al.2005) ដែលជាការដាក់សម្ពាធទៅលើធនធានបឹងទន្លេសាប។ កំឡុងពេលដែលត្រីនៅតែជាធនធានចំបងដែលអាចរកបាន ការជួញដូរទៅលើប្រភេទសត្វផ្សេងទៀតនៅបឹងជាពិសេសការជួញដូរសត្វពស់បានកើនឡើងគួរឱ្យចាប់អារម្មណ៍។ នៅពេលដែលធន-ធានត្រីកម្រ អ្នកនេសាទត្រីដែលកំពុងរស់នៅតាមបឹងបានផ្លាស់ប្តូ យុទ្ធសាស្ត្ររបស់ពួកគេពីការនេសាទត្រីទៅនេសាទសត្វពស់ទឹកដោយប្រើប្រាស់សំណាញ់។ សត្វពស់៨ប្រភេទត្រូវបានគេចាប់យ៉ាងពេញទំហឹង និងជាប្រចាំ ដែលក្នុងនោះមាន៥ប្រភេទជាអំបូររង Homalopsinae ដែលជាអំបូរពស់ទឹករបស់អាស៊ីខាងត្បូង។ វាត្រូវបានស្វែងអោយឃើញនៅក្នុងលទ្ធផលដែលគេអាចរកទិញសត្វពស់ទឹកបានយ៉ាងច្រើននៅក្នុងទីផ្សារក្នុងតំបន់ ដែលបណ្តាលឱ្យការប្រើប្រាស់សត្វពស់មានការកើនឡើង ហើយមានចំនួនសត្វពស់ដ៏ច្រើនដែលសព្វថ្ងៃនេះកំពុងដឹកជញ្ជូនពីបឹងទន្លេសាបទៅតាមក្រុងជុំវិញប្រទេសកម្ពុជា។ ពស់ទាំងនោះបានក្លាយទៅជាអាហារញ៉ាំលេងដែលពេញនិយមដែលជាទូទៅ គេទទួលទានបានទាំងចៀន ឬអាំងហើយនឹងជាញ្ញឹកញាប់ក្លែមជាមួយទឹកត្នោតជូរនៅក្នុងតំបន់។

មានទីផ្សារអន្តរជាតិសំរាប់សត្វពស់ទន្លេសាបផងដែរ (Bonheur & Lane.2002), ទាំងប្រភេទស្បែកដែលត្រូវបានប្រើជាផលិតផលច្នៃម៉ូដ ក៏ដូចជាសត្វរស់សំរាប់ការប្រើប្រាស់របស់មនុស្សផងដែរ ដែលជាញឹកញាប់មាននៅក្នុងភោជនីយដ្ឋានថ្ងៃៗ។ ទោះបីចំនួននេះនៅតិចតួចបើប្រៀបធៀបជាមួយការជួញ-ដូរក្នុងស្រុកសំរាប់ ជាអាហារក្រពើក៏ដោយ ក៏តួលេខតិចជាង៥%នៃកសិដ្ឋានឯកជនបង្ហាញថា មានផលប៉ះពាល់ទៅលើប្រភេទដែលមានតំលៃខ្ពស់។ ប្រភេទដែលកំពុងក្លាយជាគោលដៅចំបងនោះគឺ ពស់ចាន់ល្មូ (Enhydris bocourti) និងពស់កាចាន់ (Homalopsis buccata) ហើយពស់ថ្លាន់ (Python molurus) និងពស់វែក (Naja Kaouthia and N. siamensis)ក៏ត្រូវបានគេជួញដូរម្តងម្កាលផងដែរ ។

ការធ្លាក់ចុះយ៉ាងខ្លាំងនៃចំនួនសត្វពស់គ្រប់ប្រភេទដ៏ច្រើនលើសលប់ដែលត្រូវគេជួញដូរត្រូវបានរាយការណ៍ដោយអ្នកប្រមាញ់ និងអ្នកជួញដូរសត្វពស់ទឹកដែលបានលើកឡើងថាសកម្មភាពទាំងនេះមិនមានចេរភាព និងអាច




*តារាង១ : រដូវធ្វើជំនួញសត្វពស់អាស្រ័យលើចំនួនចូលចតនៅកំពង់ផែចុងឃ្នាសនៅខេត្តសៀមរាប*